# របាយការណ៍

# វគ្គបណ្តុះបណ្តាលសម្រាប់គ្រូពេទ្យស្តីពី ការគ្រប់គ្រងព្យាបាលអ្នកជំងឺអេដស៍ពេញវ័យ និងកុមារ

Training on Comprehensive ART Management for New and Existing Clinician for Adult and Pediatric HIV Care at ART Sites

នៅថ្ងៃចន្ទ ៣រោច ដល់ថ្ងៃសុក្រ ៧រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូពេទ្យ ស្តីពី ការគ្រប់គ្រងព្យាបាល អ្នកជំងឺអេដស៍ពេញវ័យ និងកុមារ ក្រោមការឧបត្ថមថវិកាគម្រោង US CDS Cambodia ដែលវគ្គនេះមានគោលបំណងដូចខាងក្រោម៖

**គោលបំណងវគ្គ៖**

- យល់ដឹងពីជំងឺវីរុសអេដស៍
- យល់ដឹងពីផ្លូវលចម្លងនៃមេរោគអេដស៍ និងកត្តាបង្កើនការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍
- យល់ដឹងការបង្ករោគ និងការវិវត្តន៍នៃមេរោគអេដស៍ និងឥទ្ធិពលនៃមេរោគអេដស៍លើប្រព័ន្ធភាពស៊ាំ។
- យល់ច្បាស់ពីជំងឺឱកាសនិយម និងជំងឺកាមរោគ
- យល់ដឹងពីឪថ្នាំARV/ART និងភាពស៊ាំថ្នាំ
- យល់ដឹងពីថ្នាំនិងការព្យាបាលជំងឺថ្លើម
- យល់ដឹងពីសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺផ្ទុកមេរោគអេដស៍
- យល់ដឹងពីជំងឺមិនឆ្លង
- ដឹងប្រព័ន្ធចំណាត់ថ្នាក់ដំណាក់កាលគ្លីនិក នៃជំងឺអេដស៍ សម្រាប់មនុស្សពេញវ័យ និងក្មេងជំទង់ ស្របតាម WHO។
- ផ្តល់ពត៌មានថ្មីៗ និងគោលការណ៍ណែនាំជាតិ ស្តីពីការថែទាំ និងព្យាបាលជំងឺអេដស៍លើមនុស្សពេញវ័យ ក្មេងជំទង់ និងកុមារដែលផ្ទុកមេរោគអេដស៍ និងកុមារដែលប្រឈមនឹងការឆ្លងមេរោគអេដស៍។
- បង្កើនការទំនាក់ទំនងរវាង គ្រូពេទ្យព្យាបាលនៅសេវាមនុស្សពេញវ័យ និងសេវាកុមារ និងចែករំលែកបទពិសោធន៍ក្នុងការថែទាំ និងព្យាបាលមេរោគអេដស៍ លើមនុស្សពេញវ័យ និងកុមារផ្ទុកមេរោគអេដស៍។






ក្នុងវគ្គនេះ **លោកវេជ្ជបណ្ឌិត ង៉ូវ ប៉ូរ៉ា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ** បានដឹកនាំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូពេទ្យ ស្តីពី ការគ្រប់គ្រងព្យាបាលអ្នកជំងឺអេដស៍ពេញវ័យ និងកុមារ ដែលប្រព្រឹត្តិទៅនៅសាលប្រជុំ Aនៃមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រោមការឧបត្ថម្ភថវិកាដោយ US-CDC មានសិក្ខាកាមអញ្ជើញចូលរួម ៨ រាជធានីខេត្ត។ វគ្គបណ្តុះបណ្តាលនេះ ក្រោមអធិបតីភាពរបស់ លោកវេជ្ជបណ្ឌិត **ង៉ូវ ប៉ូរ៉ា** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ បន្ទាប់ពីកម្មវិធីបើកវគ្គ គ្រូសម្របសម្រួលថ្នាក់ជាតិបានចាប់ផ្តើមកម្មវិធីតាមរបៀបវារៈដែលមានរយៈពេលចំនួន ៥ ថ្ងៃ។ មុននឹងចាប់ផ្តើមវគ្គបណ្តុះបណ្តាលក្រុមការងារបានឱ្យសិក្ខាកាមទាំងអស់ធ្វើតេស្តមុនវគ្គ ដើម្បីវាស់ស្ទង់ចំណេះដឹងរបស់ពួកគាត់ជាមុន ក្រោយពីវគ្គបណ្តុះបណ្តាលបានបញ្ចប់រយៈ៥ថ្ងៃ ក្រុមការងារបានឱ្យសិក្ខាកាមធ្វើតេស្តក្រោយវគ្គម្តងទៀត ជាលទ្ធផលឃើញថា សិក្ខាកាមចូលរួមមានកម្រិតចំណេះដឹងប្រហែល៦៥% ពេលធ្វើតេស្តមុនវគ្គ ហើយតេស្តក្រោយវគ្គ ៨៥% ដូចន្នេះមានការកើនឡើងនៃចំណេះដឹងរបស់ពួកគាត់ ២០%។ បន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាលរយៈពេល ៥ថ្ងៃនេះ មានការអញ្ជើញចូលរួមជាគណៈអធិបតី ពី លោកវេជ្ជ. លី វណ្ណធី អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋ អាមេរិក លោកវេជ្ជ. ង៉ូវ ប៉ូរ៉ា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ លោកវេជ្ជ. ប្រាក់ ណារុំ អនុប្រធានគ្លីនិកជាតិ ក្នុងកម្មវិធីបិទវគ្គ លោកវេជ្ជ. លី វណ្ណធី អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក មានមតិសំណេះសំណាល និងផ្តាំផ្ញើសារមួយចំនួនដែលមានសារៈសំខាន់ដល់សិក្ខាកាមដែលអាចយកទៅអនុវត្តនៅសេវារៀងៗខ្លួនឱ្យកាន់តែប្រសើរឡើង។ បន្ទាប់មក លោកវេជ្ជ. ង៉ូវ ប៉ូរ៉ា អនុប្រធានជម្ឈមណ្ឌលជាតិ មានមតិចូលរួមផ្តាំផ្ញើមួយចំនួនជូនដល់សិក្ខាកាមទាំងអស់ឱ្យយកចំណេះវិជ្ជាដែលទទួលបានពីសំណាក់គ្រូសម្របសម្រួលរបស់ថ្នាក់ជាតិដែលខិតខំបង្ហាត់បង្ហាញ

ក្នុងរយៈពេល៥ថ្ងៃនេះយកទៅជួយការងារនៅសេវា ART តាមកន្លែងរបស់យើងឱ្យបានច្រើន មិនតែប៉ុណ្ណោះយើងនៅមានគ្រូរបស់យើងចាំជួយជានិច្ចនៅពេលដែលមានសំណួរណាមិនច្បាស់លាស់ក្នុងការព្យាបាល បន្ទាប់ពីបញ្ចប់មតិផ្តាំផ្ញើ លោកវេជ្ជបណ្ឌិតបានប្រកាសបិទវគ្គបណ្តុះបណ្តាល ព្រមទាំងចែក







